អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



# កណ្ដុរទីក្រុងនិងកណ្ដុរស្រុកស្រែ

## The Country Mouse And The City Mouse


កែសម្រួលដោយ TukTuk រូបភាពដោយ
និស្សិតនៃសកលវិទ្យាល័យ
Seinan Jo Gakuin ប្រទេសជប៉ុន



កាលពីព្រេងនាយ មានកណ្ដុរពីរក្បាលជាសម្លាញ់នឹងគ្នា។ ថ្ងៃមួយកណ្ដុរទីក្រុងបានមកលេងកណ្ដុរស្រុកស្រែ។
កណ្ដុរស្រុកស្រែពិតជាសប្បាយចិត្តខ្លាំងណាស់ ហើយបានរៀបចំម្ហូបអាហារសាមញ្ញបែបស្រុកស្រែ ដើម្បីទទួលកណ្ដុរទីក្រុង។



«ហូបឱ្យឆ្អែតទៅសម្លាញ់ កុំខ្លាចចិត្តខ្ញុំអី»។ ម្ហូបមានទឹកគ្រឿង ហហ្មុក (អាម៉ុក) បាយនិងផ្លែឈើជាដើម។ កណ្ដុរទីក្រុងបានឃើញហើយក៏និយាយ «អូ ព្រះអើយ! តើឯងចូលចិត្តហូបអាហារសាមញ្ញបែបហ្នឹង? ហេតុអ្វីបានជាឯងមិនសាកទៅទីក្រុងម្ដងមើល? ព្រោះទីនោះមានអាហារឆ្ងាញ់ៗច្រើនណាស់»។



កណ្ដុរស្រុកស្រែបានសម្រេចចិត្តទៅលេងទីក្រុងម្ដង។ ទីក្រុងពិតជាធំខ្លាំងណាស់ហើយមានរ៉ឺម៉កកង់បីពាសពេញហ្នឹងតែម្ដង
«ឆាប់ឡើងៗវាមានគ្រោះថ្នាក់ណាស់ កុំដើរយឺតពេក» កណ្ដុរទីក្រុងនិយាយ។ កណ្ដុរស្រុកស្រែក៏ដើរតាមផ្លូវទាំងអារម្មណ៍ភ័យខ្លាចនិង
ស្រឡាំងកាំង។



កណ្ដុរទីក្រុងនិយាយ «ពួកយើងបានមកដល់ផ្ទះដែលខ្ញុំរស់នៅហើយ»។ កណ្ដុរស្រុកស្រែបានចូលទៅក្នុងផ្ទះបាយក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំងតែម្ដង។ នៅលើតុអាហារមានសុទ្ធតែម្ហូបអាហារប្លែកៗ ដែលវាមិនដែលបានឃើញពីមុនមកនោះទេ។
កណ្ដុរស្រុកស្រែលាន់មាត់ «អូ! ពិតជាអស្ចារ្យខ្លាំងណាស់»។




កណ្ដុរទីក្រុងនិយាយ «ហូបឱ្យច្រើនៗទៅសម្លាញ់ កុំក្រែងចិត្តអីណា»។
កណ្ដុរទាំងពីរកំពុងហូបសុខៗ ស្រាប់តែឮស្នូរជើងនរណាម្នាក់បានដើរចូលមក។
កណ្ដុរទីក្រុងនិយាយ «ពួកយើងជួបអាសន្នហើយ តស់! ទៅរកកន្លែងលាក់ខ្លួនសិន»។



«ពួកយើងត្រូវលាក់ខ្លួនឱ្យស្ងៀមស្ងាត់រហូតដល់មនុស្សចេញសិន ប្រសិនបើមិនដូច្នេះទេ ពួកយើងនឹងត្រូវគេដេញចាប់ហើយ»។
«មនុស្សចេញហើយ ពួកយើងហូបអាហារបន្ត!»។



កណ្ដុរទាំងពីរបានឡើងទៅលើតុបាយម្ដងទៀត។ បន្ទាប់មក ពួកគេបានឮស្នូរជើងមនុស្សចូលមកទៀតហើយ។
«ពួកយើងជួបអាសន្នទៀតហើយ គស់! ទៅលាក់ខ្លួនម្ដងទៀតសិន!»។ ពួកគេទាំងពីរពិតជាឃ្លានខ្លាំងណាស់
តើពួកគេត្រូវលាក់ខ្លួនបែបនេះប៉ុន្មានដងទៀត?កណ្ដុរស្រុកស្រែភ័យខ្លាចនិងមិនស្ងប់ចិត្តនោះទេ។



«ឥឡូវនេះយើងអាចចេញបានហើយ ដូច្នេះឯងហូបបានតាមសប្បាយ ចង់ហូបប៉ុណ្ណាក៏បានដែរ»។
«កុំបារម្ភណ៍អីណា ខ្ញុំនឹងហូបវាឱ្យច្រើនៗតែម្តង»។  ប៉ុន្តែភ្លាមៗនោះ កណ្តុរស្រុកស្រែអស់កម្លាំងជាខ្លាំង។



កណ្ដុរទីក្រុងសួរ «ហេតុអ្វីបានជាសម្លាញ់ឆាប់ត្រលប់ទៅផ្ទះម្ល៉េះ តើអាហារមិនឆ្ងាញ់ ឬហូបមិនឆ្អែត?»។ «ខ្ញុំចង់រស់នៅស្រុកស្រែវិញ ទោះបីជាពួកយើងមិនមានម្ហូបអាហារល្អពិសេសក៏ពិតមែនតែពួកយើងអាចហូបបានដោយមិនមានភាពភ័យខ្លាច»។ កណ្ដុរស្រុកស្រែបានលាសម្លាញ់របស់វា «លាហើយសម្លាញ់ ខ្ញុំត្រលប់ទៅផ្ទះស្រុកស្រែវិញហើយ»។ ពួកគេទាំងពីររស់នៅមានក្ដីសុខដូចគ្នា គ្រាន់តែតាមរបៀបផ្សេងគ្នាប៉ុណ្ណោះ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញនិងផ្ដោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការ R4C បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំនិងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រ ដើម្បីទទួលបានធនធានបង្រៀន៖ https//rermork.org/

ទទួលបានព័ត៌មានបន្ថែម

មូលនិធិផ្ដល់ដោយអង្គការTukTukនិងសមាគមរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគូរដោយនិស្សិតនៃសកលវិទ្យាល័យ Seinan Jo Gakuin នៃប្រទេសជប៉ុន ។
ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រី Kristen Maree Sullivan ដែលបានសហការជាមួយអង្គការដឹកនាំសម្របសម្រួលនិស្សិតស្ម័គ្រចិត្តបុគ្គលិកទាំងអស់នៅក្នុងអង្គការដោយក្ដីមេត្តាធម៌ក្នុងការបង្កើតសៀវភៅនេះឡើង។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន